# កៅអីបន្ទុប



## តើអ្វីជាកៅអីបន្ទុប?

កៅអីបន្ទុបគឺជាកៅអីទារក ដែលគ្មានរបាំងទាំងសង្ខាង ។ កៅអីនេះជួយលើកក្មេងឡើង ឲ្យខ្ពស់ដើម្បីឲ្យខ្សែក្រវ៉ាត់ លើភ្លៅ និងស្មារបស់ក្មេង ត្រូវល្មម ។ ក្មេងប្រើកៅអីបន្ទុបកាលណាខ្លួនគេធំជាងកៅអីធម្មតា តែមិនល្មមនឹងខ្សែក្រវ៉ាត់កៅអីឡានធម្មតា ។ ខ្សែក្រវ៉ាត់ ដែលមិនត្រូវល្មមនឹងខ្លួនគឺមិនអាចការពារកូនអ្នកបានឡើយ កាលណាមានគ្រោះថ្នាក់បុកគ្នា ។ កៅអីបន្ទុបអាចដោះស្រាយបញ្ហានេះបាន ។

នៅក្នុងរដ្ឋវ៉ាស៊ីនតោន ច្បាប់ចែងថាក្មេងដែលមានអាយុ រហូតដល់ យ៉ាងហោចណាស់ 6 ឆ្នាំ ឬទំងន់ 60 ផោន្ស ត្រូវជិះឡានដោយប្រើកៅអីបន្ទុប ។ តែអ្នកជំនាញផ្នែកសុវត្ថិភាពយល់ស្របថាក្មេងគួរតែប្រើកៅអីបន្ទុបរហូតដល់ អាយុ 8 ឆ្នាំ ហើយយ៉ាងហោចណាស់មានទំងន់ 80 ផោន្ស និងរហូតទាល់តែខ្សែក្រវ៉ាត់ក្នុងឡានពាក់ត្រូវល្មមខ្លួនគេ ។

កុំប្រើកៅអីបន្ទុបជាមួយតែខ្សែក្រវ៉ាត់លើភ្លៅឲ្យសោះ ។ កៅអីបន្ទុបត្រូវតែប្រើជាមួយខ្សែក្រវ៉ាត់លើភ្លៅ និងស្មា ។

## ឡានរបស់ខ្ញុំមានតែខ្សែក្រវ៉ាត់លើភ្លៅនៅកន្លែងជិះខាងក្រោយ ។ តើខ្ញុំអាចធ្វើអ្វី?

សាកល្បងប្រើជំរើសណាមួយខាងក្រោម៖

- ប្រើកៅអីបន្ទុបនៅកន្លែងជិះកៅអីខាងមុខជាមួយខ្សែក្រវ៉ាត់លើភ្លៅ និងស្មា ។ រុញកៅអីឡានខាងមុខនោះមកខាងក្រោយឲ្យឆ្ងាយ បើអាចធ្វើបានដើម្បីរក្សាកូនអ្នកឲ្យឆ្ងាយពីប៉ាណ្ណូខាងមុខ ។
- កុំដាក់កូនអ្នកឲ្យជិះកៅអីខាងមុខឲ្យសោះ បើសិនជាឡានរបស់អ្នកមានស្បោងខ្យល់ ។
- បើសិនជាអ្នកត្រូវតែប្រើខ្សែក្រវ៉ាត់លើភ្លៅ កូនរបស់អ្នក ត្រូវប្រើវាឲ្យទាប ហើយរឹតឲ្យតឹងព័ទ្ធត្រគាគ ។
- ទូរស័ព្ទមកអង្គការ Safety Restraint Coalition តាមលេខ 425-828-8975 ឬលេខ 1-800-282-5587 (1-800-BUCK-L-UP) សំរាប់ជំរើស ផ្សេងទៀត ។

## តើមានកៅអីបន្ទុបប៉ុន្មានប្រភេទ?

កៅអីបន្ទុបមានពីរប្រភេទ ។

- កៅអីបន្ទុបដែលគ្មានបង្អែកអាចប្រើនៅក្នុងឡានដែលមានប្រដាប់កល់ក្បាល នៅត្រង់កៅអីជិះខាងក្រោយ ឬបង្អែកពីក្រោយដែលមានកំពស់លើត្រចៀកកូនអ្នកកាលណាគេអង្គុយនៅលើកៅអីបន្ទុប ។
- កៅអីបន្ទុបមានបង្អែកអាចប្រើនៅក្នុងឡានដែលមាន ឬគ្មានប្រដាប់កល់ក្បាល ។



កៅអីបន្ទុបគ្មានបង្អែក



កៅអីបន្ទុបមានបង្អែក

## ដើម្បីចង់បានពត៌មានច្រើនថែមទៀត

- អញ្ជើញពិនិត្យទំព័រវ៉ិបសៃយ៍របស់អង្គការ Booster Seat Coalition នៅ www.boosterseat.org
- ទូរស័ព្ទមកអង្គការ Safety Restraint Coalition, លេខ 425-828-8975 ឬលេខ 1-800-282-5587 (1-800-BUCK-L-UP)
- អញ្ជើញពិនិត្យទំព័រវ៉ិបសៃយ៍របស់អង្គការ Safety Restraint Coalition នៅ www.800bucklup.org

HARBORVIEW INJURY PREVENTION & RESEARCH CENTER · WASHINGTON Traffic Safety COMMISSION · Children's Hospital & Regional Medical Center Seattle, Washington · WASHINGTON STATE 1800 BUCK-L-UP SAFETY RESTRAINT COALITION · Injury Free coalition for Kids® of Seattle

© 2004 Children's Hospital and Regional Medical Center

Pub. 12/04 (DL)
CE484
[Khmer]